NSW GOVERNMENT | Education & Communities

# Getting ready for school

## A guide for parents of a child with disability

# ការប្រុងប្រៀបរួចជាស្រេចដើម្បីចូលរៀន

## សេចក្តីណែនាំសំរាប់មាតាបិតានៃក្មេងដែលមានពិការភាព







Khmer



ការចាប់ផ្ដើម Kindergarten គឺជាដំណាក់កាលមួយដ៏រំភើបក្នុងជីវិតរបស់ក្មេងគ្រប់រូប។ ការជ្រើសរើសសាលារៀនសំរាប់កូនរបស់លោកអ្នក គឺជាការសម្រេចចិត្តដ៏ធំ ហើយចំពោះមាតាបិតានៃក្មេងដែលមានពិការភាព ដំណើរការនេះអាចទាក់ទិនជាមួយកិច្ចការជាច្រើន។

ការណែនាំនេះបានរៀបចំឡើង ដើម្បីជួយលោកអ្នកពីដើមដល់ចប់ ក្នុងដំណើរការរៀបចំសំរាប់ និងជ្រើសរើសសាលារៀនមួយដែលសមស្របបំផុតទៅតាមសេចក្ដីត្រូវការរបស់កូនលោកអ្នក។

## កន្លែងដែលត្រូវចាប់ផ្តើម

- ប្រសិនបើលោកអ្នកមានកូនដែលមានពិការភាព លោកអ្នកត្រូវបានណែនាំឲ្យទាក់ទងជាមួយនរណាម្នាក់ក៏បាន គឺសាលារៀនក្នុងតំបន់ ឬការិយាល័យប្រចាំតំបន់របស់លោកអ្នកឲ្យបាន ១២ខែមុនពេលកូនរបស់លោកអ្នកចាប់ផ្តើមចូលរៀន។ ការនេះនឹងផ្តល់ជូនលោកអ្នកនូវឱកាសដើម្បីពិភាក្សាអំពីសេចក្តីត្រូវការផ្នែកអប់រំដ៏ជាក់លាក់ និងការផ្គត់ផ្គង់របស់កូនលោកអ្នកជាមួយបុគ្គលិកដែលពាក់ព័ន្ធ។

- ពេលណាកូនរបស់លោកអ្នកមានសេចក្តីត្រូវការដែលតម្រូវឲ្យមានការរៀបចំការធ្វើដំណើរចេញចូលនៅតាមទីកន្លែងជាក់លាក់ណាមួយ លោកអ្នកត្រូវបានណែនាំឲ្យទាក់ទងដំបូងជាមួយសាលារៀនក្នុងតំបន់ ឬការិយាល័យប្រចាំតំបន់របស់លោកអ្នកឲ្យបាន២ឆ្នាំ មុនពេលកូនរបស់លោកអ្នកចាប់ផ្តើមចូលរៀន។ ការនេះនឹងផ្តល់ពេលសំរាប់ក្រសួងដើម្បីធ្វើឲ្យប្រាកដថា ជំរើសចូលរៀនរបស់លោកអ្នកត្រូវបានគេសម្គាល់ដឹង ហើយហេដ្ឋារចនាសម្ព័ន្ធទាំងឡាយត្រូវបានរៀបចំរួចស្រេច នៅពេលកូនរបស់លោកអ្នកចាប់ផ្តើមចូលរៀន។

- នៅពេលលោកអ្នកមកជួបនាយកសាលា សូមយកមកជាមួយលោកអ្នកនូវឯកសារនៃការវាយតម្លៃផ្នែកពេទ្យ និងផ្នែកព្យាបាលរោគពេលថ្មីៗ ដែលមានការពាក់ព័ន្ធដើម្បីចែករំលែកឲ្យគេបានដឹងឮ។

- និយាយជាមួយសមាជិកនៃបណ្តាញផ្គត់ផ្គង់របស់លោកអ្នក (ឧទាហរណ៍ គ្រួសារ មិត្តភក្តិ វេជ្ជបណ្ឌិត គ្រូពេទ្យព្យាបាលកូនក្មេង ក្រុមអ្នកគាំទ្រ បណ្តាញអ្នកមានពិការភាព អ្នកព្យាបាលជម្ងឺដោយធ្វើចលនា អ្នកចិត្តសាស្រ្ត អ្នកព្យាបាលឲ្យមានសមត្ថភាពក្នុងការងារឡើងវិញ អ្នកព្យាបាលជម្ងឺក្នុងការនិយាយស្តី និងបញ្ចេញសម្លេង) និងមាតាបិតាឯទៀតដែលមានកូនមានពិការភាពនៅសាលា អំពីបទពិសោធន៍របស់គេ។

- សាលាមត្តេយ្យរបស់លោកអ្នក ឬកិច្ចបំរើដទៃទៀតសំរាប់កុមារភាពនៅអាយុបឋមវ័យ ក៏អាចជួយក្នុងការផ្លាស់ប្តូរទៅសាលារៀនបានដែរ។ ប្រសិនបើកូនរបស់លោកអ្នកពុំបានទទួលការផ្គត់ផ្គង់ពីកិច្ចបំរើទាំងនេះទេ លោកអ្នកអាចទំនាក់ទំនងមកសាលារៀនក្នុងតំបន់ ឬការិយាល័យប្រចាំតំបន់របស់លោកអ្នក ដែលអាចផ្តល់ជូនកម្មវិធីពិសេសសំរាប់ការផ្លាស់ប្តូរទៅសាលារៀននៅក្នុងតំបន់របស់លោកអ្នក។ លោកអ្នកអាចទំនាក់ទំនងមកការិយាល័យប្រចាំតំបន់របស់លោកអ្នកតាមទូរស័ព្ទលេខ 131 536 ពីទូរស័ព្ទតាមផ្ទះរបស់លោកអ្នក។





## ជំរើសចុះឈ្មោះចូលរៀន

- ពេញទូទាំងរដ្ឋ NSW ក្រសួងអប់រំ និងសហគមន៍ (Department of Education and Communities) (DEC) ផ្តល់ជូនកិច្ចបំរើផ្សេងៗជាច្រើន ដើម្បីផ្គត់ផ្គង់សិស្សដែលមានសេចក្តីត្រូវការពិសេស
- ក្នុងថានៈជាមាតាបិតា ឬអ្នកមើលថែក្មេងដែលមានពិការភាពពិតប្រាកដ លោកអ្នកអាចពិចារណាអំពីជំរើសផ្នែកអប់រំដូចតទៅនេះ:

  - សាលារៀនក្នុងតំបន់របស់លោកអ្នក

  - ថ្នាក់ពិសេសមួយ នៅក្នុងសាលារៀនដ៏ទៀងទាត់មួយ

  - សាលារៀនពិសេសមួយ (សាលារៀនសំរាប់គោលបំណងដ៏ជាក់លាក់)។

## ការរកបានជំរើសចូលរៀនដ៏ត្រឹមត្រូវ

នាយកសាលា ក្នុងការពិគ្រោះយោបល់ជាមួយក្រុមផ្គត់ផ្គង់និងរៀនសូត្ររបស់សាលារៀន នឹងជួយលោកអ្នកដើម្បីរកជំរើសចូលរៀនដ៏ត្រឹមត្រូវសំរាប់កូនរបស់លោកអ្នក ដោយគិតពិចារណាទៅលើជំរើសរបស់លោកអ្នក ការរៀនសូត្រដ៏ជាក់លាក់របស់កូនលោកអ្នក និងសេចក្តីត្រូវការផ្គត់ផ្គង់ និងចម្ងាយដែលនៅជិតកិច្ចបំរើអ្នកឯកទេសក្នុងតំបន់។ ការិយាល័យប្រចាំតំបន់នៅតាមកន្លែងរបស់លោកអ្នក ក៏អាចជួយលោកអ្នកដើម្បីរកជំរើសដ៏ត្រឹមត្រូវមួយសំរាប់កូនរបស់លោកអ្នកដែរ។

## ការចុះឈ្មោះចូលរៀនសំរាប់ក្មេងដែលមានពិការភាព

- ការចុះឈ្មោះចូលរៀនក្នុងថ្នាក់ដ៏ទៀងទាត់មួយ ត្រូវបានធ្វើឡើងតាមរយៈសាលារៀនក្នុងតំបន់របស់លោកអ្នក។
- ការចុះឈ្មោះចូលរៀនក្នុងថ្នាក់ពិសេសមួយ ឬក្នុងសាលារៀនពិសេសមួយ ត្រូវបានធ្វើឡើងតាមរយៈដំណើរការមួយដែលគេស្គាល់ថា ក្រុមរកទីកន្លែងរៀនប្រចាំតំបន់។
- លោកអ្នកអាចទទួលពត៌មានអំពីការនេះ ដោយទំនាក់ទំនងមកការិយាល័យប្រចាំតំបន់របស់លោកអ្នក តាមទូរស័ព្ទលេខ 131 536 ពីទូរស័ព្ទតាមផ្ទះរបស់លោកអ្នក។

## ការធ្វើបញ្ជីចំរាញ់ឈ្មោះសាលារៀន

- លោកអ្នកអាចប្រើប្រាស់ប្រព័ន្ធរកសាលារៀនតាមអ៊ីនធើណិត ដើម្បីសម្គាល់ឲ្យដឹងសាលារៀនក្នុងតំបន់របស់លោកអ្នកនៅត្រង់:
  www.schools.nsw.edu.au/schoolfind/locator/
  នៅទីនេះ លោកអ្នកអាចរកតាមប្រភេទសាលារៀន ដើម្បីស្វែងរកសាលារៀនពិសេសដែលគេស្គាល់ថាជាសាលារៀនសំរាប់គោលបំណងដ៏ជាក់លាក់ ក៏ប៉ុន្តែសូមចងចាំថាការចុះឈ្មោះចូលរៀននៅតាមកន្លែងទាំងនេះ ចាំបាច់ត្រូវការចាត់ចែងតាមរយៈការិយាល័យប្រចាំតំបន់របស់លោកអ្នក។ លោកអ្នកអាចទំនាក់ទំនងមកការិយាល័យប្រចាំតំបន់របស់លោកអ្នកតាមទូរស័ព្ទលេខ 131 536 ពីទូរស័ព្ទតាមផ្ទះរបស់លោកអ្នក។
- ធ្វើការណាត់ជួបជាមួយនាយកសាលាក្នុងតំបន់របស់លោកអ្នក ដើម្បីពិភាក្សាអំពីជំរើស និងសេចក្តីត្រូវការដ៏ជាក់លាក់របស់កូនលោកអ្នក។ មាតាបិតាជាច្រើនរកបានការផ្គត់ផ្គង់ដោយនាំមិត្តភក្តិ ឬសាច់ញាតិមកជាមួយគេ។
- សូមយកឯកសារនៃការវាយតម្លៃផ្នែកពេទ្យនៅពេលថ្មីៗទាំងអស់មកជាមួយលោកអ្នកក្នុងការប្រជុំនេះ ដើម្បីឲ្យលោកអ្នកអាចចែករំលែកជាមួយបុគ្គលិករបស់ក្រសួង។
- លោកអ្នកប្រហែលជាចង់រៀបចំធ្វើបញ្ជីសំនួរ ឬកង្វល់ដែលលោកអ្នកមាន អំពីសេចក្តីត្រូវការផ្នែកអប់រំរបស់កូនលោកអ្នកដើម្បីពិភាក្សានៅពេលការប្រជុំ។



## ការផ្តត់ផ្គង់បន្ថែម

ប្រសិនបើកូនរបស់លោកអ្នកមានពិការភាព ឬការលំបាករៀនសូត្រ ហើយត្រូវការការផ្គត់ផ្គង់បន្ថែមនៅសាលារៀន សូមទំនាក់ទំនងជាមួយនាយកសាលារបស់កូនលោកអ្នក ឬការិយាល័យប្រចាំតំបន់នៅទីកន្លែងរបស់លោកអ្នក។

មាតាបិតា និងអ្នកមើលថែគឺជាប្រភពពត៌មានដ៏សំខាន់អំពីភាពខ្លាំង សមត្ថភាព និងសេចក្តីត្រូវការរបស់កូនគេ។ ភាពជាដៃគូដ៏មានប្រសិទ្ធិភាពរវាងមាតាបិតា និងសាលារៀន ទំនងជានាំឲ្យមានលទ្ធផលល្អប្រសើរសំរាប់សិស្ស។

ក្រុមរៀនសូត្រ និងផ្គត់ផ្គង់នៅតាមសាលារៀននីមួយៗជួយដល់គ្រូក្នុងថ្នាក់រៀន ដើម្បីបំពេញទៅតាមសេចក្តីត្រូវការផ្នែកអប់រំនៃសិស្សរបស់គេ។ មាតាបិតា និងអ្នកមើលថែមានតួនាទីដ៏សំខាន់ចាំបាច់ក្នុងកិច្ចការរបស់ក្រុមរៀនសូត្រ និងផ្គត់ផ្គង់ ដោយការចូលរួមក្នុងការពិភាក្សា និងការរៀបគ្រោងការសំរាប់សេចក្តីត្រូវការរបស់កូនគេ។

សាលារៀនរដ្ឋ NSW ផ្តល់ជូនការផ្គត់ផ្គង់បន្ថែមសំរាប់សិស្សដែលមានពិការភាព ឬមានការលំបាករៀនសូត្រតាមរបៀបផ្សេងៗមួយចំនួន អាស្រ័យទៅលើសេចក្តីត្រូវការរបស់សិស្សម្នាក់ៗផ្ទាល់។

ការផ្គត់ផ្គង់នេះអាចរាប់បញ្ចូលទាំង:

- ការផ្លាស់ប្តូរដែលគ្រូធ្វើនៅក្នុងថ្នាក់រៀន ចំពោះកម្មវិធីបង្រៀន និងរៀនសូត្ររបស់គេរាល់ថ្ងៃ
- លទ្ធភាពទទួលបានបុគ្គលិកអ្នកឯកទេសផ្នែកជំនាញការដែលផ្គត់ផ្គង់សិស្ស និងគ្រូក្នុងថ្នាក់រៀនរបស់គេ
- ជំនួយបន្ថែមក្នុងថ្នាក់រៀន មកពីបុគ្គលិកផ្គត់ផ្គង់
- ការផ្គត់ផ្គង់សម្ភារៈ និងគ្រឿងបរិក្ខារសំរាប់អ្នកឯកទេស
- លទ្ធភាពទទួលបានការហ្វឹកហ្វឺននៃអ្នកឯកទេស សំរាប់គ្រូ និងបុគ្គលិកផ្គត់ផ្គង់។

## ការទទួលបានផលប្រយោជន៍ច្រើនបំផុត ពីសាលារៀន

- ពេលណាលោកអ្នកបានជ្រើសរើសទីកន្លែងរៀនសូត្រសំរាប់កូនរបស់លោកអ្នកហើយ សូមរក្សាការទាក់ទងតាមលទ្ធភាពធ្វើបាន។ ការលើកតម្កើងទំនាក់ទំនងវិជ្ជមានជាមួយគ្រូ និងសាលារៀនរបស់កូនលោកអ្នក នឹងជួយឲ្យបុគ្គលិកសាលារៀនស្គាល់លោកអ្នក និងកូនរបស់លោកអ្នកកាន់តែច្បាស់ឡើង។

- សូមមានទំនាក់ទំនងឲ្យបានទៀងទាត់ ជាមួយគ្រូរបស់កូនលោកអ្នក ដើម្បីឲ្យលោកអ្នកអាចបន្តពិភាក្សាអំពីកម្មវិធីរៀនសូត្រ និងភាពជឿនលឿនរបស់កូនលោកអ្នក និងបញ្ហាថ្មីៗណាមួយដែលអាចកើតមានចំពោះលោកអ្នក ឬសាលារៀន។

- ពិភាក្សាអំពីរបៀបមានប្រសិទ្ធិភាពបំផុត ដើម្បីរក្សាការប្រាស្រ័យទាក់ទងល្អរវាងអ្នកនៅតាមផ្ទះរបស់លោកអ្នក និងសាលារៀន។ ក្នុងឋានៈជាមាតាបិតា លោកអ្នកស្គាល់កូនរបស់លោកអ្នកច្បាស់បំផុត។ សូមឲ្យលោកអ្នកបានជាអ្នកផ្គត់ផ្គង់សំខាន់បំផុតរបស់កូនលោកអ្នក។

- ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយលោកអ្នកទំនាក់ទំនងជាមួយសាលារៀន សូមទូរស័ព្ទមកកិច្ចបំរើអ្នកបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់លោកអ្នក។ អ្នកលើកទូរស័ព្ទ នឹងទូរស័ព្ទទៅសាលារៀន ហើយរៀបចំអ្នកបកប្រែភាសាតាមទូរស័ព្ទ ដើម្បីជួយលោកអ្នកនៅក្នុងការសន្ទនារបស់លោកអ្នក។ ពេលណាអាចធ្វើបាន សាលារៀននឹងរៀបចំឲ្យមានអ្នកបកប្រែភាសាសំរាប់ការប្រជុំនៅសាលារៀនប្រសិនបើត្រូវការ។ កិច្ចបំរើទាំងនេះនឹងពុំគិតថ្លៃពីលោកអ្នកឡើយ។








## ធនធានបន្ថែមទៀត

- www.schools.nsw.edu.au/gotoschool/enrolment/index.php (វិបសាយជាភាសាអង់គ្លេស)
- តើអ្នកណានឹងបង្រៀនកូនខ្ញុំ? *(Who's Going to Teach My Child?)* (មានជាភាសាអង់គ្លេសប៉ុណ្ណោះ) www.schools.nsw.edu.au/media/downloads/schoolsweb/studentsupport/programs/lrngdificulties/whoteach.pdf
- DVD ស្ពានចម្លងដ៏សំខាន់បំផុត (Critical Bridges DVD) (មានជាភាសាអង់គ្លេសប៉ុណ្ណោះ) www.det.nsw.edu.au/detresources/critbridges_YKSeRaDPnn.pdf
- DVD ការចាប់ផ្តើមចូលរៀន (Starting School DVD) (ធនធានមានផ្តល់ជាភាសា អារ៉ាប់ ចិនកន្តាំង ដារី ឌីនកា អង់គ្លេស កូរ៉េ ចិនកុកងឺ និងវៀតណាម)។ សូមទូរស័ព្ទ Gowrie NSW លេខ (02) 8571 9700 ដើម្បីបញ្ជាទិញមួយដុំ។

**NSW Department of Education and Communities**

**លេខទូរស័ព្ទការិយាល័យប្រចាំតំបន់**
**Regional office contact numbers**

| | |
|---|---|
| Hunter/Central Coast | 4924 9999 |
| Illawarra & South Coast | 4222 2929 |
| New England | 6755 5934 |
| North Coast | 6652 0500 |
| Northern Sydney | 9886 7690 |
| Riverina | 6937 3871 |
| South Western Sydney | 9796 5446 |
| Sydney | 9217 4877 |
| Western NSW | 6841 2110 |
| Western Sydney | 9208 9359 |

## ទំនាក់ទំនងរបស់ខ្ញុំ (My contacts)

សាលារៀនក្នុងតំបន់: (Local school:)

ឈ្មោះនាយកសាលា: (Principal name:)

ទូរស័ព្ទ: (Phone:)

កំណត់ចំណាំ: (Notes:)

ការិយាល័យក្នុងតំបន់: (Regional office)

ឈ្មោះសំរាប់ទំនាក់ទំនង: (Contact name)

ទូរស័ព្ទ: (Phone:)

កំណត់ចំណាំ: (Notes:)

© April 2012

NSW Department of Education and Communities

GPO Box 33
Sydney NSW 2001
Australia
T (02) 9561 8000
www.det.nsw.edu.au

NSW GOVERNMENT | Education & Communities